01597360

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 12 / 2018
ម៉ោង (Time/Heure): 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E378/8/13

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

សម្ងាត់ / Confidential / Confidentiel

**Declassified to Public 25 January 2019**

**ប្រធានគណៈមេធាវី**

**មេធាវី សួន វិសាល**

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី កុយ នាម
២-មេធាវី នេព បុផល
៣-មេធាវី ពេជ្រ សុរិយោ
៤-មេធាវី ជុំ សុខវណ្ណាលី
៥-មេធាវី ម៉ា ខូនកា
៦-មេធាវី ចេង ម៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនឃួន
៩-មេធាវី សេ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូច ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឌុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុផារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ចំនួ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុគា
១៩-មេធាវី ឈាប គុណផុល
២០-មេធាវី យឹម ថាវី
២១-មេធាវី អ៊ឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុគំព្រួ
២៧-មេធាវី គាន គាព
២៨-មេធាវី ម៉ាង ហុង
២៩-មេធាវី ឈរ លីវ៉ែ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ឡូន ផានិត
៣៣-មេធាវី ឃុត កែវសុផ្លា

លេខ ២៦៩០ /គម/១៨

**សូមជម្រាបមក**

**លោកប្រធានអង្គភាពគាំពារការពារក្តី**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)**

**កម្មវត្ថុ** ÷ ករណីលោក Victor Koppe ។

**យោង** ÷ សេចក្តីសម្រេចលេខ ៥១៥/សសគម/១៨ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់គណៈមេធាវី ស្តីពីការដាក់មេធាវីបរទេសលោក Victor Koppe ជាសហមេធាវីអន្តរជាតិការពារក្តីឱ្យលោក **នួន ជា** ក្នុងសំណុំរឿង00២/0២ ឱ្យនៅក្រៅបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

តបតាមកម្មវត្ថុ និងយោងខាងលើ គណៈមេធាវីសូមជម្រាបជូន **លោកប្រធាន** ជ្រាបថា៖ លោក Victor Koppe ត្រូវបានគណៈមេធាវីសម្រេចឱ្យនៅក្រៅបញ្ជីនៃសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី0៩ ខែសីហា ឆ្នាំ២០១៨ តាមសេចក្តីសម្រេចដែលបានយោងខាងលើ និងបានលុបឈ្មោះចេញពីបញ្ជីរបស់គណៈមេធាវីរួចហើយ(អនុលោមតាមប្រការ៥នៃសេចក្តីសម្រេចនេះ) ។ ប៉ុន្តែកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ លោក Victor Koppe នៅតែបន្តប្រើប្រាស់តួនាទីជាមេធាវីតាមរយៈការចូលរួមក្នុងនីតិវិធីប្រកាសសាលក្រមសង្ខេបរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក និងការធ្វើសន្និសីទសារព័ត៌មានក្នុងឋានៈជាសហមេធាវីអន្តរជាតិការពារក្តីលោក **នួន ជា** ។ ការបន្តពាក់អាវវិជ្ជាជីវៈមេធាវី ប្រើប្រាស់តួនាទីជាមេធាវី និងចូលរួមក្នុងនីតិវិធីរបស់តុលាការដែលប្រព្រឹត្តឡើងដោយលោក Victor Koppe ក្រោយពីគាត់ត្រូវបានលុបឈ្មោះចេញពីបញ្ជីគណៈមេធាវីរួចហើយ នោះគឺជាអំពើរំលោភបំពានលើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងសេចក្តីសម្រេចរបស់គណៈមេធាវី ហើយអំពើនេះអាចត្រូវផ្តន្ទាទោសតាមមាត្រា ៧៧ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ ខ្ញុំសូមបញ្ជាក់ថា សេចក្តីសម្រេចរបស់គណៈមេធាវីនៅតែមានអានុភាពអនុវត្ត ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ (ប្រការ៥នៃសេចក្តីសម្រេចខាងលើ) ។ ព្រោះថានេះជាសេចក្តីសម្រេចរបស់ស្ថាប័នឯករាជ្យមួយ ហើយពុំមានបទប្បញ្ញត្តិណាមួយកំណត់ឱ្យផ្អាកការអនុវត្តសេចក្តីសម្រេចរបស់គណៈមេធាវី នៅពេលដែលមានបណ្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចនេះឡើយ ។ ក្នុងករណីមានសេចក្តីសម្រេចរបស់ស្ថាពររបស

អាគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរសព្ទ: 0២៣ ៦២២ ៧0៧0, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sensok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh/ Website: www.bakc.org.kh

សាលាឧទ្ធរណ៍ ឬតុលាការកំពូលលុបចោលសេចក្តីសម្រេចរបស់គណៈមេធាវី ទើបក្រុមប្រឹក្សាគណៈមេធាវីនឹងលើកយកករណីរបស់លោក Victor Koppe មកសម្រេចឡើងវិញ។បច្ចុប្បន្នលោក Victor Koppe ពុំមានឈ្មោះក្នុងបញ្ជីគណៈមេធាវីទៀត។ ដូច្នេះគាត់មិនអាចប្រកបវិជ្ជាជីវៈមេធាវីបានឡើយ។

គណៈមេធាវីសង្ឃឹមថា **លោកប្រធាន** នឹងសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចលេខ ៥១៥/សសគម/១៨ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់គណៈមេធាវី និងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ដើម្បីជៀសវាងនូវផលវិបាកផ្នែកគតិយុត្តដែលកើតចេញពីការប្រកបវិជ្ជាជីវៈមេធាវីដោយខុសច្បាប់ពីសំណាក់លោក Victor Koppe។

សូម **លោកប្រធាន** មេត្តាទទួលនៅការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃអង្គារ ៤កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨

**ត.ប.ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**អគ្គលេខាធិការ**




មេធាវី. ភ្លុយ_នាម

**ចំលងជូន÷**

-សាលាដំបូង អ.វ.ត.ក

-តុលាការកំពូល អ.វ.ត.ក

-សាលាឧទ្ធរណ៍ភ្នំពេញ

-តុលាការកំពូល

"ដើម្បីជូនជ្រាប"